# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល និងមហាអយ្យការ
អមតុលាការកំពូល
លេខ ៣៨៨ .តកក.សរវ

## ប្រធានតុលាការកំពូល

**គោរពជូន**

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កម្មវត្ថុ:** អំពីការសុំអនុវត្តសាលដីកាស្ថាពររបស់តុលាការកំពូលចំនួនពីរ ពាក់ព័ន្ធដល់លិខិតជូនដំណឹងរបស់ ទីស្តីការគណៈរដ្ឋមន្ត្រី ។

**យោង:** លិខិតលេខ ១១៦១ លស ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

សេចក្តីដូចមាននៅក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមអនុញ្ញាតជម្រាបជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី ដូចតទៅ ៖

១-ករណីឈ្មោះ ឈិន សុឃាង និង ស្រី ភាន មានជម្លោះរឿងដី ហើយប្តឹងចូលដល់តុលាការនៅ ថ្ងៃទី១៦-០៣-២០០០ ឈ្មោះស្រី ភាន បានចាញ់ក្តីនៅតុលាការគ្រប់ជាន់ថ្នាក់ ។ មកដល់ឆ្នាំ២០០២ តុលាការកំពូលបានសម្រេចសេចក្តីជាស្ថាពរឱ្យឈ្មោះស្រី ភាន ចាញ់ក្តីទៀត តាមសាលដីកាលេខ ៣០០ ចុះថ្ងៃទី២៦-១២-២០០២ នៅឆ្នាំ២០០៣ ឈ្មោះស្រី ភាន ក៏បែរមកប្តឹងជារឿងព្រហ្មទណ្ឌវិញម្តង ចោទប្រកាន់ពីបទក្លែងលិខិត ។ ក្រសួងយុត្តិធម៌បន្ទាប់ពីបានស៊ើបអង្កេតរួចហើយ បានធ្វើរបាយការណ៍ជូនសម្តេចនាយករដ្ឋមន្ត្រី តាមលិខិតលេខ ៤៤៣ អកកយ ២០០៤ ចុះថ្ងៃទី១២-០៥-២០០៤ ក្នុងនោះលើកសំណើ ៣ចំណុច ៖

១-សុំជួយអន្តរាគមន៍រកយុត្តិធម៌ជូនប្រជារាស្ត្ររងគ្រោះឈ្មោះ ឈិន សុឃាង ដែលត្រូវឈ្មោះស្រី ភាន ប្រឌិតភស្តុតាងថ្មី ក្រោយពេលខ្លួនចាញ់ក្តីដើម្បីឱ្យតុលាការបន្ទាយមានជ័យចោទប្រកាន់ ។

២-សុំតម្កល់សាលដីការបស់តុលាការកំពូល ទុកជាបានការដដែល ។

៣-សុំអនុវត្តលិខិតលេខ ៣៥០ អកកយ ២០០៤ ចុះថ្ងៃទី៥-០៤-២០០៤ ។ សម្តេចនាយក យល់ព្រមតាមសំណើទាំង ៣ចំណុច ។

តាមរយៈសេចក្តីជូនដំណឹងលេខ ៥១៥ សជណ ចុះថ្ងៃទី២០-៥-២០០៤ ទីស្តីការគណៈរដ្ឋមន្ត្រីជម្រាបមកឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អោយចាត់ចែងអនុវត្តន៍នូវចំណុចទាំង៣ខាងលើ អាស្រ័យហេតុនេះទើបសាលដីការបស់តុលាការកំពូលត្រូវបានអនុវត្តដោយប្រគល់ដីទំនាស់អោយមកឈ្មោះឈិន យុឃាង កាន់កាប់តទៅ ។ ស្រាប់តែនៅថ្ងៃទី១០-០៤-២០០៦ គឺរយៈពេល២ឆ្នាំក្រោយមក ក៏មានសជណ មួយទៀត លេខ ៥៨៥ បង្គាប់ឱ្យចាត់ចែងចុះបញ្ជីដីធ្លីឱ្យលោកស្រី ភាន ទៅវិញ ។

២-ករណីឈ្មោះ ហុក ហាយ និងឈ្មោះតី សារ៉ន មានជំលោះក្នុងរឿងដីធ្លី ហើយប្តឹងចូលដល់តុលាការនៅថ្ងៃទី៣០-១២-១៩៩៨ ។ រឿងនេះឈ្មោះហុក ហាយ បានចាញ់ក្តីឈ្មោះតី សារ៉ន នៅតុលាការខេត្ត និងនៅសាលាឧទ្ធរណ៍ នៅពេលដែលតុលាការកំពូលកំពុងចាត់របៀបស៊ើបអង្កេតបន្ថែស្រាប់តែមានសេចក្តីជូនដំណឹងលេខ ៦១៦៧ សជណ ចុះថ្ងៃទី២៧-១២-៦០០៥ បង្គាប់ឱ្យចេញប័ណ្ណកម្មសិទ្ធិស្របច្បាប់ឱ្យប្រជាជន៣គ្រួសារក្នុងនោះមានហុក ហាយ ផងដែរ ។ ដោយតុលាការកំពូលមិនបានទទួល សជណ លេខ ២១២៧ នេះ ក៏ចាត់ការរឿងក្តីនេះបន្ត

ដាក់ជំនុំជម្រះចេញសាលដីកាស្ថាពរលេខ ១០៣ ចុះថ្ងៃទី២១-៤-២០០៦ ប្រគល់ដីទំនាស់ឱ្យឈ្មោះតឺ សារ៉ន កាន់កាប់ ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា តាមមាត្រា១២៨ថ្មី សម្រេចឱ្យតុលាការគ្រប់ជាន់ថ្នាក់មានសមត្ថកិច្ចសម្រេចគ្រប់រឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ហើយសេចក្តីសម្រេចរបស់តុលាការគ្រប់ជាន់ថ្នាក់ សុទ្ធតែធ្វើឡើងដោយសវនាការជាសាធារណៈ ។

មុនសវនាការតុលាការត្រូវឱ្យគូភាគីជូនសំអាងរៀងៗខ្លួន ក្នុងករណីចាំបាច់ តុលាការធ្វើការស៊ើបអង្កេតបន្ថែម ពេលធ្វើសវនាការ គូភាគីមានសិទ្ធិធ្វើការតវ៉ាតទល់គ្នា បង្ហាញពីទឡ្ហីករណីការពារផលប្រយោជន៍រៀងៗខ្លួន រួមទាំងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីនគូភាគីផង ។ គូភាគីនៃរឿងក្តីមានសិទ្ធិប្តឹងឧទ្ធរណ៍ ឬ សាទុក្ខពីការសម្រេចរបស់តុលាការខេត្ត-ក្រុង ឬ សាលាឧទ្ធរណ៍ដូចៗគ្នា ក្នុងករណីដែលសាមីខ្លួនមិនពេញចិត្តពីការសម្រេចនៃសាលាជម្រះក្តីទាំងពីរថ្នាក់នេះ ។

ឯសេចក្តីជូនដំណឹងរបស់ស្ថាប័ននានា បើជូនដល់តុលាការមុនការជំនុំជម្រះ តុលាការនឹងចាត់ទុកជាភស្តុតាងដែលត្រូវពិចារណា ដោយឡែកចំពោះសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី បើមកដល់តុលាការកំពូលមុនការជំនុំជម្រះ ហើយបើពិនិត្យទៅឃើញថា ផ្ទុយនឹងសេចក្តីសម្រេចរបស់តុលាការនោះ តុលាការកំពូលផ្អាកការចាត់ការរឿងក្តីបន្តមួយរយៈសិន ។

ចំពោះសាលដីកាស្ថាពររបស់តុលាការកំពូលលេខ ២៥ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៤ និងសាលដីកាស្ថាពរលេខ ១០៣ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៦ ពុំមានចំណុចណាខុសទៅនឹងច្បាប់សារាចរ សេចក្តីណែនាំលិខិតបទដ្ឋាន និងយុត្តិសាស្ត្រកន្លងមកទេ ។ ហើយតាមមាត្រា ២០៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌដែលមានអានុភាពក្នុងរឿងក្តីរដ្ឋប្បវេណីផងដែរ សាលដីកាខាងលើនេះ មិនអាចប្តឹងតវ៉ា ឬ សម្រេច ទុកជាមោឃៈឬកែប្រែបានទេក្រៅពីអនុវត្តតាមប៉ុណ្ណោះ ។

សូម ឯកឧត្តម មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៦

**ឱក មុន្នី**